**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០១៥ សហវ.ពម

រាជធានីភ្នំពេញ,ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១៣

# សេចក្តីជូនដំណឹង

## ស្តីពីការផ្ទេរអតិរេកថវិការបស់រដ្ឋបាលឃុំ សង្កាត់ និងរដ្ឋបាលក្រុង ស្រុក ទៅក្នុងគណនីមូលនិធិបំរុងប្រើប្រាស់សម្រាប់ហិរញ្ញប្បទាន ឲ្យចំណាយជាមូលធននៃថវិកាឆ្នាំបន្ទាប់

យោងទៅតាមលិខិតបទដ្ឋានគតិយុត្តិជាធរមានស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់ និង ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រុង ស្រុក បានកំណត់អតិរេកថវិការបស់រដ្ឋបាលឃុំនៅដំណាច់ឆ្នាំថវិកាត្រូវផ្ទេរទៅ គណនីមូលនិធិបំរុងដែលនឹងត្រូវបានប្រើប្រាស់សម្រាប់ហិរញ្ញប្បទានដល់ចំណាយជាមូលធននៃថវិកាឆ្នាំបន្ទាប់ រីឯអតិរេកថវិការបស់រដ្ឋបាលសង្កាត់ និងរដ្ឋបាលក្រុង ស្រុកនៅដំណាច់ឆ្នាំថវិកាត្រូវផ្ទេរទៅគណនីលទ្ធផលនៃ រតនាគាររាជធានី ខេត្ត។

បច្ចុប្បន្នដោយពិនិត្យឃើញថាថវិការបស់រដ្ឋបាលឃុំ សង្កាត់ និងរដ្ឋបាលក្រុង ស្រុកនៅមានទំហំ តូចហើយធនធានហិរញ្ញវត្ថុគឺបានមកតែពីប្រភពមូលនិធិមួយមុខប៉ុណ្ណោះ។ ម្យ៉ាងទៀតដោយការយល់ដឹងអំពី ជំនាញបច្ចេកទេសផ្នែកហិរញ្ញវត្ថុរបស់មន្ត្រីថ្នាក់ក្រោមជាតិនៅមានកំរិតនៅឡើយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញ វត្ថុសម្រេចអនុញ្ញាតឲ្យរដ្ឋបាលឃុំ សង្កាត់ និងរដ្ឋបាលក្រុង ស្រុកផ្ទេរអតិរេកថវិកានៅដំណាច់ឆ្នាំទៅក្នុង គណនីមូលនិធិបំរុងដើម្បីប្រើប្រាស់សម្រាប់ហិរញ្ញប្បទានដល់ចំណាយមូលធននៃថវិកាឆ្នាំបន្ទាប់រហូតដល់ មានការណែនាំជាថ្មី។

ទទួលបានសេចក្តីជូនដំណឹងនេះ សូមឯកឧត្តមអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត លោក អភិបាលនៃគណៈអភិបាលក្រុង ស្រុក លោកប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត លោកប្រធាន រតនាគារ រាជធានី ខេត្ត លោកនាយកទីចាត់ការហិរញ្ញវត្ថុរាជធានី ខេត្ត លោកប្រធានការិយាល័យរដ្ឋបាលនិង ហិរញ្ញវត្ថុក្រុង ស្រុក លោកមេឃុំ និងលោកចៅសង្កាត់មេត្តាជ្រាប និងសហការគ្នាសម្របសម្រួលគាំទ្រឲ្យការ រៀបចំនិងអនុវត្តថវិការបស់រដ្ឋបាលឃុំ សង្កាត់ និងរដ្ឋបាលក្រុង ស្រុកប្រព្រឹត្តទៅដោយសង្គតិភាព។ ក្នុង ករណីជួបបញ្ហាប្រឈមត្រូវរាយការណ៍ជាបន្ទាន់មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតាមរយៈនាយកដ្ឋានហិរញ្ញវត្ថុ មូលដ្ឋាន។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**<u>កន្លែងទទួល:</u>**

-លេខាធិការដ្ឋាន គ.ជ.អ.ប (ជាពត៌មាន)
-អគ្គនាយកដ្ឋានរតនាគារជាតិ
-នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន
-សាលារាជធានី ខេត្ត
-គ្រប់សាលាក្រុង ស្រុក
-គ្រប់សាលាឃុំ សង្កាត់
(ដើម្បីអនុវត្ត)
-គ្រប់មន្ទីរហិរញ្ញវត្ថុរាជធានី ខេត្ត
-គ្រប់រតនាគាររាជធានី ខេត្ត
-គ្រប់ទីចាត់ការហិរញ្ញវត្ថុរាជធានី ខេត្ត
(ដើម្បី គាំទ្រនិងសម្របសម្រួល)
-ឯកសារ